
Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org

# 1.01 កាលដើមដំបូងបង្អស់

**លោកុប្បត្តិ ១:១ - ២:៣**
នៅពេលវេលាដែលបានចាប់ផ្តើម មានតែព្រះមួយអង្គគត់ ពេលនោះគ្មានអ្វីសោះ ហើយគ្មាននរណាម្នាក់ផ្សេងទៀតឡើយ ។
ព្រះអម្ចាស់ជាអ្នកដែលបង្កើត អ្នកសាងសង់និងជាសិល្បៈករម្នាក់ ។ ទ្រង់តែងតែមានផែនការធំៗ !

ពិភពលោកដែលគ្មានអ្វីសោះ គឺងងឹតសូន្យសុង ។ ផែនការដំបូងរបស់ព្រះ គឺធ្វើឱ្យមានពន្លឺ ។ ទ្រង់មានព្រះបន្ទូលថា "ចូរឱ្យមានពន្លឺ" ហើយពន្លឺបានកើតឡើងសម្រាប់ពិភពលោក ។ ព្រះដ៏ជាេព្រះទ្រង់ហៅផ្នែកដែលមានពន្លឺថាជា "ថ្ងៃ" និងផ្នែកងងឹតថាជា "យប់" ។

នៅថ្ងៃទីពីរព្រះទ្រង់មានព្រះបន្ទូលថា "យើងនឹងញែកដីគោកចេញពីទឹក" ហើយទ្រង់បានហៅលំហពីលើទឹកថា" មេឃ" ។

នៅថ្ងៃទី ៣ ព្រះទ្រង់បានបង្កើតដី - ដែលពេញដោយរុក្ខជាតិ, ផ្កា, ព្រៃ និងភ្នំ ។

នៅថ្ងៃទីបួន ព្រះទ្រង់បានដាក់ពន្លឺដែលភ្លឺបំផុត - គឺព្រះអាទិត្យ - នៅលើមេឃនៅពេលថ្ងៃ ហើយទ្រង់បានដាក់ព្រះច័ន្ទ និងផ្កាយសម្រាប់ពេលយប់ ។

នៅថ្ងៃទីប្រាំ ព្រះទ្រង់មានព្រះបន្ទូលថា៖ «ចូរឲ្យទឹកពេញទៅដោយរបស់មានជីវិត ហើយឲ្យសត្វស្លាបហើរលើអាកាសពីលើដី ។

បន្ទាប់មកនៅថ្ងៃទីប្រាំមួយព្រះទ្រង់បានបង្កើតសត្វលូនវារ លូនលោតនិងពពៃល ។

មនុស្សដំបូងមានឈ្មោះថា អ័ដាម ហើយបន្ទាប់មកទ្រង់បានបង្កើតប្រពន្ធរបស់គាត់ ឈ្មោះថា អេវ៉ា ។ ព្រះទ្រង់បានបង្កើតមនុស្សតាមរូបអង្គទ្រង់ ។ ដូច្នេះអ្នកក៏ត្រូវបានបង្កើត ឲ្យមានលក្ខណៈដូចព្រះដែរ! ផ្នែកនីមួយៗ "ល្អ" - ត្រី ដី ផ្កាយ និងមនុស្ស គឺល្អទាំងអស់ ។

ព្រះទ្រង់បានឈប់សម្រាក បន្ទាប់ពីទ្រង់បានទតឃើញរបស់ទាំងប៉ុន្មាន ដែលទ្រង់បានបង្កើត សុទ្ធតែល្អៗ ។ ទ្រង់ក៏បានយកថ្ងៃទី ៧ ជាថ្ងៃឈប់សម្រាក ដោយមិនធ្វើអ្វីទៀតទេ ។ ផែនដីត្រូវបានរួចរាល់ ហើយអ្វីៗដែលនៅក្នុងនោះគឺល្អ ។

**ទំនុកដំកើង ១៣៩:១៤** "ទូលបង្គំ សូមលើកតម្កើងព្រះអង្គ ដ្បិតទូលបង្គំជាស្នាព្រះហស្តដ៏ល្អអស្ចារ្យ ទូលបង្គំដឹងច្បាស់ថា អ្វីៗ ដែលព្រះអង្គ ធ្វើ សុទ្ធតែល្អអស្ចារ្យទាំងអស់" ។

## 1.01 ការធ្លាក់ចុះសេចក្តីណែនាំ-សម្រាប់គ្រូបង្រៀន
## កំណត់សំគាល់

១. គ្រប់របស់ទាំងអស់គឺល្អឥតខ្ចោះ នៅពេលព្រះទ្រង់បានបង្កើតផែនដីមក ។ គឺគ្មានអំពើរបាបទេ ។ គ្មានការមិនស្តាប់បង្គាប់។ ព្រះទ្រង់បានប្រទានសួនច្បារដ៏ស្រស់ស្អាតមួយឲ្យអ័ដាម និងអេវ៉ាសម្រាប់រស់នៅ ។ យ៉ាងណាក៏ដោយ គឺមានបញ្ញត្តិយ៉ាងសំខាន់មួយ ។ មិនត្រូវបរិភោគផ្លែឈើដឹងខុសត្រូវ" ល្អ និងអាក្រក់ឡើយព្រះបាន "ប្រាប់ពួកគេ ។

២. អារក្សសាតាំង វាគឺជាខ្មាំងសត្រូវរបស់ព្រះអម្ចាស់ ។ វាបានក្លែងខ្លួនជាសត្វពស់ ហើយនិយាយប្រាប់អេវ៉ាថា មិនអីទេក្នុងការដែលបរិភោគផ្លែដឹងខុសត្រូវនោះ ។ នាងបានបរិភោគវា ហើយឲ្យខ្លះទៅប្តីរបស់នាង គឺជាលោកអ័ដាម ។

៣. ព្រះទ្រង់ព្រួយព្រះទ័យខ្លាំងណាស់ ។ ទ្រង់បានដឹងថា អ័ដាម និងអេវ៉ាបានស្តាប់តាមសម្តីអារក្សសាតាំង ។ ឥឡូវ ពួកគេត្រូវបានដាច់ចេញពីព្រះដោយសារបាបរបស់គេ ។ ដោយហេតុនេះហើយ សេចក្តីអាក្រក់ទាំងឡាយបានចូលមកលើផែនដីនេះ ។

៤. គឺមានតែវិធីម្យ៉ាងប៉ុណ្ណោះ ដើម្បីដោះស្រាយស្ថានភាពដ៏អាក្រក់នេះបាន ។ ព្រះនឹងបញ្ជូននរណាម្នាក់ដើម្បីសង្គ្រោះមនុស្សលោកពីអំពើរបាបរបស់ពួកគេ ។ ព្រះបានយាងមកលើផែនដីនេះ ជាមនុស្សម្នាក់ គឺព្រះនាម (យេស៊ូវ) ។ ព្រះយេស៊ូវនឹងត្រូវសុគតដើម្បីលោះយកបាបចេញ ។

៥. នៅពេលយើងទទួលជឿព្រះយេស៊ូវ យើងអាចទូលសូមព្រះអង្គឲ្យទ្រង់អត់ទោសបាបដល់យើងបាន ។ ហើយយើងនឹងអាចនៅជាប់នឹងព្រះអង្គម្តងទៀត ។

**សំណួរ**

១) តើវាបានចាប់នៅពេលណា? តើនរណាបាននៅទីនោះ?

២) តើព្រះបានបង្កើតអ្វីមុនគេបង្អស់?

៣) តើអ្នកដាក់ឈ្មោះរបស់ទាំងអស់ដែលព្រះបានបង្កើត?

៤) តើព្រះបានបង្កើតនរណាអោយដូចរូបទ្រង់?

៥) តើព្រះបានធ្វើអ្វីនៅថ្ងៃទីប្រាំពីរ?

**ចម្លើយ**

1 ) កាលដើងដំបូងបង្អស់មានព្រះអម្ចាស់។

2) ព្រះបានបង្កើតពន្លឺជាមុនដំបូង។

៣) ព្រះបានបង្កើតរុក្ខជាតិ សត្វ ផែនដី មេឃ និងពន្លឺនៅលើមេឃ។

៤) ព្រះបានបង្កើតមនុស្សដូចជារូបអង្គទ្រង់។ ទ្រង់បានបង្កើតមនុស្សដំបូងគឺអ័ដាម និងប្រពន្ធរបស់អ័ដាមគឺអេវ៉ា។

5) នៅថ្ងៃទីប្រាំពីរ ព្រះអម្ចាស់បានឈប់សម្រាក។

**ទំនុកដំកើង១៣៩:១៤** ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់ ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ។



www.kidsofdestiny.org